# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

************

តុលាការកំពូល

---

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៨៨

ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០១

សាលដីកា

លេខ : ៥៧

ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០០២

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ជីវ កេង ជាចៅក្រម

៣- លោក គង់ គីរុន ជាចៅក្រម

៤- លោក យស់ សួខឿន ជាចៅក្រម

៥- លោក ប៉ែន សារឿន ជាចៅក្រម របាយការណ៍

ក្រឡាបញ្ជី

លោក សុង ម៉ៅ

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា លេខ ៨៦ " ឈ " ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០១ នៃ សំណុំរឿងរដ្ឋប្បវេណី លេខ ៣៥៨ ចុះថ្ងៃទី ១៦ខែឧសភា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ។

- រវាងដើមចោទឈ្មោះ ហាំង គង់ " ចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅ ផ្ទះគ្មានលេខ ផ្លូវ ហារ វិ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ វេង ឃុន " ស " ម្តាយឈ្មោះ សៀម អេង " ស " ប្រពន្ធឈ្មោះ លឹម មុំ ។

- និងចុងចម្លើយឈ្មោះនាវ ស៊ាន "ដើមបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៣២ឆ្នាំ ជាតិតៃវ៉ាន់ មុខរបរ ពាណិជ្ជករ ទីលំនៅផ្ទះ ២៥៤Eo ផ្លូវលេខ ១៨៣ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ ហ្វាង ចុងអ៊ី " រ " ម្តាយឈ្មោះ និម ពី " រ " ប្រពន្ធឈ្មោះ ឌី ហួយ ។

មានមេធាវី អ្នកស្រី ពិង ធីតា

- តតិយជន ក្រុមហ៊ុន Grand Power Concret Enterprise តំណាងដោយឈ្មោះ វ៉ាង ជុងជីង ផ្ទេរសិទ្ធិឱ្យមេធាវី ម៉ៅ សំវុទ្ធារី ។

- អំពីវិវាទៈ ប្តឹងសុំឱ្យអនុវត្ត និង គោរពតាមកិច្ចសន្យាទិញលក់ដី ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៨២ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១ របស់ លោក ១៣

ពុធ ធារី មេធាវី តំណាងឱ្យ ចុងចម្លើយ ប្តឹងមិនសុខចិត្ត ពីសាលដីកា រដ្ឋប្បវេណី លេខ ៨៦ " ឈ " ចុះ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ២៨៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០១ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៧-១១-២០០០ របស់ឈ្មោះ ហ៊ាង គង់ ប្តឹងសុំឱ្យអនុវត្ត និង គោរពតាមកិច្ចសន្យាទិញលក់ដី ពីឈ្មោះ នាវ ស៊ាន ដោយសំអាងហេតុថា ខ្លួន និង ក្រុមហ៊ុន Grand Power Concret Enterprise បានទិញដីហើយ មិនបានប្រគល់ប្រាក់ឱ្យមកខ្លួនគ្រប់ចំនួន ។

តាមពាក្យបណ្តឹងសុំចូលជាតតិយជនរបស់មេធាវី ម៉ៅ សំវុទ្ធារី តំណាងក្រុមហ៊ុន Grand Power Concret Enterprise ដោយហេតុថា ការទិញលក់ដី គឺ ហ៊ាង គង់ បានលក់ឱ្យក្រុមហ៊ុន ជ ឈ្មោះ នាវ ស៊ាន គ្រាន់តែជា តំណាងក្នុងការទិញលក់ប៉ុណ្ណោះ និង សុំឱ្យបដិសេធដីកាសំរេចកិច្ចការប្រញាប់ លេខ ១៦ ប្រ ខ. ចុះថ្ងៃទី ០៦-១២-២០០០ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១៦ " ខ " ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ហ៊ាង គង់ ចុះថ្ងៃទី ២៧-១១-២០០០ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលថាការផ្ទេរសិទ្ធិពីក្រុមហ៊ុន Grand Power Concret Enterprise មក ឱ្យមេធាវី ម៉ៅ សំវុទ្ធារី ចុះថ្ងៃទី ១៩-១២-២០០០ ចូលជាតំណាង និង អ្នកការពារ ជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- ទទួលថា ពាក្យសុំថណាយក្តី ចុះថ្ងៃទី ២៥-១២-២០០០ របស់មេធាវី ពុធ ធារី ជាអ្នកការពារក្តីឱ្យ នាវ ស៊ាន ជាត្រឹមត្រូវតាមច្បាប់ ។

៤- ទទួលពាក្យបណ្តឹងចូលជាតតិយជន ចុះថ្ងៃទី ២១-១២-២០០០ របស់មេធាវី ម៉ៅ សំវុទ្ធារី ទុកជា ត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៥- បង្គាប់ឱ្យឈ្មោះ ហ៊ាង គង់ និង ក្រុមហ៊ុន Grand Power Concret Enterprise អនុវត្តកិច្ចព្រមព្រៀងរបស់ខ្លួន គឺក្រុមហ៊ុនត្រូវបង់ចំនួន ២៤.០០០$ ( ពីរម៉ឺនបួនពាន់ដុល្លាអាមេរិក ) សំរាប់ ៣ខែ ដំបូង ចាប់ពីខែ ១១-១២-២០០០ ដល់ខែ ០១ ឆ្នាំ ២០០១ ហើយចាប់ពីខែ ០២ ឆ្នាំ ២០០១ តទៅ ក្រុមហ៊ុនត្រូវបង់ក្នុងមួយខែ ចំនួន ៧.០០០$ ( ប្រាំពីរពាន់ដុល្លាអាមេរិក ) ជារៀងរាល់ខែ រហូតដល់គ្រប់ចំនួន ២៨០.០០០$ ( ម្ភៃប្រាំបីម៉ឺនដុល្លាអាមេរិក ) ឱ្យទៅឈ្មោះ ហ៊ាង គង់ ។

៦- បង្គាប់ឱ្យលុប ឈ្មោះនាវ ស៊ាន និង លី ហ៊ុយ ចេញពីវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ៩០២៤ ចុះថ្ងៃទី ១៣-០៥-៩២ ហើយដាក់ជារបស់ក្រុមហ៊ុន Grand Power Concret Enterprise វិញ ៕

៧- បង្គាប់ឱ្យក្រុមហ៊ុន Grand Power Concret Enterprise បង់ប្រាក់ប្រដាប់ក្ដីគឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ៣០០០រៀល រង្វាន់សាក្សី ២០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ កាលបើផុតបណ្ដឹងឧទ្ធរណ៍ បង្គាប់ឱ្យក្រុមហ៊ុននេះសងប្រាក់ ៧០០០រៀល ទៅដើមចោទវិញ ហើយឱ្យបង់ពន្ធសមាមាត្រចំនួន ១% លើទឹកប្រាក់ត្រូវសងចំនួន ២៨០.០០០$ ( ម្ភៃប្រាំបីម៉ឺនដុល្លាអាមេរិក ) ត្រូវជា ២៨០០$ ( ពីរពាន់ប្រាំបីរយដុល្លាអាមេរិក ) ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០% និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ % ។

៨- សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី និង តតិយជនខាងចុងចម្លើយ មេធាវីរបស់ចុងចម្លើយ និង មេធាវីរបស់តតិយជន បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ០៩ " ខ " ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០១ របស់ឈ្មោះ នាវ ស៊ាន ប្ដឹងមិនសុខចិត្ត នឹង សាលក្រមលេខ ១៦ " ខ " ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល នៃ សាលក្រម ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៨៦ " ឈ " ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៩-៤-២០០១ របស់ឈ្មោះ នាវ ស៊ាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយខាងសនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៦ " ខ " ចុះថ្ងៃទី ១៥-០២-២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣- ទុកសិទ្ធិឱ្យឈ្មោះនាវ ស៊ាន ជាចុងចម្លើយ ប្ដឹងទាមទារប្រាក់ចំនួន ៦០.០០០ដុល្លាអាមេរិក ( ប្រាំមួយម៉ឺនដុល្លាអាមេរិក ) ពីក្រុមហ៊ុន Grand Power Concret Enterprise នៅតុលាការថ្នាក់ក្រោម ។

៤- កាត់យកប្រាក់ប្រដាប់ក្ដី ជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វឹងចំនួន ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះចំនួន ៥.០០០រៀល និង អាជ្ញាធរតុលាការចំនួន ៥.០០០រៀល ។ នៅពេលសាលដីកានេះចូលជាស្ថាពរបង្គាប់ឱ្យចុងចម្លើយ បង់សងទៅដើមចោទវិញ ។

៥- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ មេធាវីតំណាងចុងចម្លើយ កំបាំងមុខតតិយជន តែចាត់ទុកជាចំពោះមុខ ។

បើកផ្លូវប្ដឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងសាទុក្ខលេខ ២៨២ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០១ របស់លោក ...

ពុធ ធារី មេធាវីតំណាងឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណី លេខ ៨៦ " ឈ " ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុច សេចក្តី វិនិច្ឆ័យទាំងមូល ។

បានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា :

- បណ្តឹងសាទុក្ខរបស់ចុងចម្លើយធ្វើឡើងស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។
- សាលដីការដ្ឋប្បវេណីលេខ ៨៦ " ឈ " ចុះថ្ងៃទី ២៦-០៦-២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ

បានស្តាប់ចម្លើយរបស់ឈ្មោះ ហ៊ាង គង់ ឆ្លើយថា : ខ្លួននៅតែសុំរក្សាឱ្យគោរពតាមកិច្ចសន្យា ទិញ-លក់ ដី ដូចមានក្នុងកម្មវត្ថុបណ្តឹងដដែល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ម៉ៅ សំរុទ្ធារី ជា មេធាវី តំណាងក្រុមហ៊ុនGrand Power Concret Enterprise បញ្ជាក់ថា : ក្នុងនាងខ្ញុំ ជាតំណាងឱ្យក្រុមហ៊ុន គឺ នៅតែសុំឱ្យគោរពតាមកិច្ចសន្យាលក់-ទិញ ដី ដូចមានក្នុងកម្មវត្ថុបណ្តឹងដដែល ។ ចំពោះលុយ ៦ម៉ឺនដុល្លារអាមេរិក ឈ្មោះ ឆាវ ស៊ាន បានប្តឹងទៅតុលាការរួចហើយ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមចោទ និង សេចក្តីសន្និដ្ឋានរបស់មេធាវីគតិយុជន.
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ.

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៨២ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១ របស់លោក ឆាវ ស៊ាន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថា តាមកិច្ចសន្យាលក់-ទិញ អចលនវត្ថុ ចុះថ្ងៃទី ៥-៥-២០០០ រវាងដើមចោទ លោក ហ៊ាង គង់ និង ប្រពន្ធអ្នកស្រី លឹម មុំ ជាភាគី ( ក ) និង ចុងចម្លើយឈ្មោះ ឆាវ ស៊ាន ជាតំណាងឱ្យក្រុមហ៊ុន ហ្គ្រែន ផៅវ័រ ខុនគ្រីត អ៊ិនធឺប្រាយ (Grand Power Concret Enterprise ) ជាភាគី ( ខ ) ពិតជាបានទិញដីពី ភាគីដើមចោទក្នុងតម្លៃ ៦០.០០០ USD ពិតប្រាកដមែន ហើយដែលដើមចោទ ក៏បានអះអាងថា ខ្លួនបានលក់ដីឱ្យទៅក្រុមហ៊ុន ហ្គ្រែន ផៅវ័រ ខុនគ្រីត អ៊ិនធឺប្រាយ គឺ ពុំមែនលក់ទៅឱ្យបុគ្គល ឆាវ ស៊ាន ទេ ។

- យល់ឃើញថា តាមលិខិតឯកភាព ផ្ទេរសិទ្ធិ អចលនវត្ថុ ចុះថ្ងៃទី ០៩-០៧-២០០០ និង កិច្ចសន្យា ចុះថ្ងៃទី ១៤-៨-២០០០ ឈ្មោះ ឆាវ ស៊ាន និង ប្រពន្ធ បានព្រមព្រៀងផ្ទេរសិទ្ធិ កាន់កាប់ដីដែលមានវិញ្ញាបនប័ត្រ សំគាល់ម្ចាស់អចលនវត្ថុលេខ ៩០២៤ ចុះថ្ងៃទី ១៣-០៥-១៩៩២ មកឱ្យក្រុមហ៊ុន ប្រ៉ែល្តន ផាវ៉ែរ ខុនត្រ៊ីត អ៊ិនធីប្រាយ វិញ ហើយនេះបញ្ជាក់ ឱ្យឃើញថា ឈ្មោះ ឆាវ ស៊ាន ទទួលស្គាល់ថាខ្លួន ពិតជាតំណាង ក្នុងការឈរឈ្មោះ ទិញដី ពីដើមចោទ ឱ្យ តតិយជន ដែលជាក្រុមហ៊ុន ប្រ៉ែល្តន ផាវ៉ែរ ខុនត្រ៊ីត អ៊ិនធីប្រាយ ពិតប្រាកដមែន ។

- យល់ឃើញថា លោក ឆាវ ស៊ាន បានដាក់ពាក្យបណ្តឹង ចុះថ្ងៃទី ២៧-១០-២០០០ ទៅ តុលាការក្រុងភ្នំពេញ ទាមទារប្រាក់ពីក្រុមហ៊ុន ប្រ៉ែល្តន ផាវ៉ែរ ខុនត្រ៊ីត អ៊ិនធីប្រាយ តាមកិច្ចសន្យា ចុះថ្ងៃទី ១៤-៨-២០០០ រួចហើយ ។

- យល់ឃើញថា តតិយជន ជាក្រុមហ៊ុន ប្រ៉ែល្តន ផាវ៉ែរ ខុនត្រ៊ីត អ៊ិនធីប្រាយ បានប្រគល់ប្រាក់ថ្លៃទិញដី មួយចំនួន ឱ្យទៅដើមចោទរួចហើយ ហើយប្រាក់ដែលនៅសល់ពុំទាន់សងនោះ ដើមចោទ និង ក្រុមហ៊ុន បានឯកភាពគ្នា ក្នុងការទូរទាត់បន្ត ហើយដែរ ។

- យល់ឃើញថា តតិយជន ពុំបានមកចូលរួមនាសវនាការនេះទេ ប៉ុន្តែមេធាវី របស់តតិយជន បានមកចូលរួមហើយ ដូច្នេះ តុលាការកំពូល ជំនុំជំរះ កំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា មេធាវីរបស់លោក ឆាវ ស៊ាន បានទទួលលិខិតបង្គាប់ឱ្យធ្វើសារណារួចហើយ ហើយក៏បានសុំពន្យាពេល ១០ ថ្ងៃ ថែមទៀត ប៉ុន្តែ លោក ឆាវ ស៊ាន នៅតែពុំបានជូនសារណារបស់ខ្លួន មកតុលាការកំពូល ទេ ហើយពុំបានមកចូលរួមនាសវនាការនេះដែរ ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការផ្តប្បវេណីលេខ ៨៦ " ឈ " ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទំរង់ និង តតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ និង តតិយជន ប៉ុន្តែចាត់ទុកជាចំពោះមុខ.

១- ទទួលបណ្តឹងសាទុក្ខលេខ ២៨២ ចុះថ្ងៃទី ១៧-៨-២០០១ របស់លោក ឆាវ ស៊ាន ធ្វើឡើងត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធ ចោល ដោយខុសនឹងតតិច្បាប់ ។

២- តម្កល់សាលដីការផ្តប្បវេណីលេខ ៨៦ " ឈ " ចុះថ្ងៃទី ២៦-០៦-២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ដែលដើមចោទ បានបង់រួចហើយ នៅតុលាការកំពូល ចំនួន ១៩.០០០រៀល គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤០០០ រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ១៥.០០០រៀល សរុបចំនួន ១៩.០០០រៀល ហើយ ពម្រូវឱ្យក្រុមហ៊ុន ហ្វ្រែន ផាវ៉ែរ ខុនគ្រីត អ៊ិនធឺប្រាយ សងប្រាក់ចំនួន ១៩.០០០រៀល ទៅលោក ហាំង គង់ វិញ និង បង្គាប់ឱ្យក្រុមហ៊ុន Grand Power Concret Enterprise បង់ពន្ធសមាមាត្រ តាមការ កំណត់ របស់តុលាការក្រុងភ្នំពេញ ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០០២ ។